ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ០៤ ខែឧសភា ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែឧសភា ឆ្នាំ២០១៤

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែឧសភា ឆ្នាំ២០១៤ របស់អគ្គនាយកដ្ឋានពន្ធដារ អង្គប្រជុំដឹកនាំដោយឯកឧត្តម **គង់ ទិត្យរិទ្ធិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមឯកឧត្តមអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម **គង់ ទិត្យរិទ្ធិ** បានសំដែងអំណរសាទរដល់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារ ដែលសម្រេចបានប្រចាំខែឧសភា ឆ្នាំ២០១៤ និងជំរុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារ សមាជិកអង្គប្រជុំដែលជាតំណាងមន្ត្រីពន្ធដារទូទាំងប្រទេសឲ្យខិតខំជំនះការលំបាក និងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទ ឲ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងបង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានល្អប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែងនិងអនុវត្តវិធានការនានា សំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៤។



ក្នុងខែឧសភា ឆ្នាំ២០១៤នេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ៣៦៤,៧៤១ លានរៀល (គិតជាដុល្លារ ៩១.២ លានដុល្លារ)។ ប្រសិនបើប្រៀបធៀប

ទៅនឹងចំណូលពន្ធប្រចាំខែឧសភា ឆ្នាំ២០១៣ មានការកើនឡើងស្មើនឹង ២៥.៤% ក្នុងនោះថវិការដ្ឋកើនឡើងចំនួនស្មើនឹង ៣៦.៧%។

ក្នុងរយៈពេលប្រាំខែនៃឆ្នាំ២០១៤ អគ្គនាយកដ្ឋានពន្ធដារប្រមូលចំណូលពន្ធដារ និងបង់ចូលថវិកាជាតិបានចំនួនស្មើនឹង៤៥.៧៧%នៃគោលដៅកំណត់ដោយច្បាប់ ក្នុងនោះថវិការដ្ឋសម្រេចបានចំនួនស្មើនឹង ៤៨.៤% និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រេចបានចំនួនស្មើនឹង ២៩.១%។ បើប្រៀបធៀបនឹងរយៈពេលប្រាំខែដូចគ្នានៃឆ្នាំ២០១៣ ឃើញថា ការប្រមូលចំណូលពន្ធដារចូលថវិកាជាតិសម្រាប់រយៈពេលប្រាំខែនៃឆ្នាំ២០១៤នេះ មានការកើនឡើងចំនួនស្មើនឹង ១២.៥% ក្នុងនោះរួមមានថវិការដ្ឋកើនឡើងចំនួនស្មើនឹង ១៤.៦%។

តាមការវិភាគប្រភេទពន្ធឃើញថា ចំណូលក្នុងឆ្នាំ២០១៤ មានការកើនឡើងគ្រប់ប្រភេទពន្ធ ក្នុងនោះប្រភេទពន្ធសំខាន់ៗដែលមានការកើនឡើងមានដូចជា ពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ ១៩.២% ពន្ធលើប្រាក់ចំណេញមានការកើនឡើងប្រមាណ ១៩.៨% និង អាករលើតម្លៃបន្ថែមមានការកើនឡើងប្រមាណ ៥.៩% និងអាករពិសេសកើនឡើងប្រមាណ ៤.៥%។




ការពិនិត្យតាមវិស័យឃើញថា ចំណូលក្នុងឆ្នាំ២០១៤ មានការកើនឡើងស្ទើរគ្រប់សកម្មភាពក្នុងនោះ ផ្នែកសេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ២០% ផ្នែកស្ថាបត្យកម្មនិងសំណង់កើនឡើងប្រមាណ ៦១.៧% ផលិតភេសជ្ជៈកើនឡើងប្រមាណ ១៥.៨% ផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ២៦.៣% ផលិតសម្លៀកបំពាក់កើនឡើងប្រមាណ ៥៧.៨% ផ្នែកសណ្ឋាគារនិងផ្ទះសំណាក់កើនឡើងប្រមាណ ៤១.៩% នីហរ័ណអាហរ័ណកើនឡើងប្រមាណ ១១.៦% ទូរគមនាគមន៍កើនឡើងប្រមាណ ៣.២% ដឹកជញ្ជូននិងទេសចរណ៍កើនឡើងប្រមាណ ១៨.៨% លក់ភេសជ្ជៈកើនឡើងប្រមាណ ៤៩.៤% ផលិតថ្នាំជក់កើនឡើងប្រមាណ ១៩.៩% លក់សម្ភារការិយាល័យកើនឡើងប្រមាណ ៤៤.៩%ផលិតម្ហូបអាហារកើនឡើងប្រមាណ ៩៣.១% អាកាសយានដ្ឋាននិងកំពង់ផែកើនឡើងប្រមាណ ១២.៣% ផ្នែកលក់គ្រឿងយន្តកើនឡើងប្រមាណ ៤៥.៨% និងលក់គ្រឿងសំណង់ កើនឡើងប្រមាណ ១៥៧១.៥% ។

ក្នុងការពិភាក្សាអង្គប្រជុំបានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា I-របាយការណ៍ប្រមូលចំណូលពន្ធ និងបញ្ហាប្រឈមរបស់នាយកដ្ឋាននិងសាខាពន្ធដារខេត្ត-ខណ្ឌក្នុងខែឧសភា ឆ្នាំ២០១៤កន្លងមក II-របាយការណ៍វឌ្ឍនភាពស្តីពីការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤ និងពន្ធលើអចលនទ្រព្យសម្រាប់ឆ្នាំ២០១៤ III-ការអប់រំស្តីពីប្រព័ន្ធពន្ធដារនិងការផ្តល់សេវាជូនអ្នកជាប់ពន្ធ (ការចុះបញ្ជី និងការស្នើសុំ VAT Certificate) IV-របាយការណ៍របស់សាខាពន្ធដារខេត្ត-ខណ្ឌ ស្តីពី÷ ១) ការធ្វើសវនកម្ម លទ្ធផលធ្វើសវនកម្ម និងការកំណត់ហានិភ័យក្នុង

ការជ្រើសរើសសហគ្រាសសម្រាប់ធ្វើសវនកម្ម ២) ការប្រមូលបំណុលពន្ធ និងការកំណត់បំណុលពន្ធដែលមិនអាចប្រមូលបាន ៣) ការប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ និងការប្រមូលពន្ធលើស្លាកយីហោ និង V- បញ្ហាផ្សេងៗ។

ដើម្បីប្រមូលចំណូលបានគ្រប់តាមផែនការច្បាប់សម្រាប់ឆ្នាំ២០១៤ និងបណ្តាឆ្នាំបន្តបន្ទាប់ខាងមុខ ជាពិសេសដើម្បីធានាបាននូវភាពជឿទុកចិត្តផ្នែកថវិកាសម្រាប់បម្រើកិច្ចការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងជំរុញការអនុវត្តឱ្យកាន់តែជោគជ័យថែមទៀត នូវកំណែទម្រង់ស៊ីជម្រៅសំខាន់ៗរបស់រាជរដ្ឋាភិបាលនីតិកាលទីប្រាំនៃរដ្ឋសភា ជាពិសេសការបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ អគ្គនាយកដ្ឋានពន្ធដារត្រូវខិតខំប្រឹងប្រែង ÷

- បន្តពង្រីកនិងពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធឱ្យកាន់តែប្រសើរឡើង ដូចការជួយសម្រួលជូនអ្នកជាប់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ អាចទៅបង់ពន្ធនិងទទួលយកលតាបត្រនៅតាមសាខាធនាគារកាណាឌីយ៉ា ក.អ កម្ពុជា ឬនៅតាមសាខាធនាគារអេស៊ីលីដា ភីអិលស៊ី។ ជាមួយគ្នានេះ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីបញ្ចូលទិន្នន័យរបស់អ្នកជាប់ពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទ រួចហើយនឹងចេញប័ណ្ណសម្គាល់ការបង់ពន្ធជូនម្ចាស់មធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទទាំងអស់ ដើម្បីបង្កភាពងាយស្រួលជូនអ្នកជាប់ពន្ធចំពោះការបង់ពន្ធលើកក្រោយៗទៀត ដោយពុំចាំបាច់បំពេញឯកសារជាថ្មីម្តងទៀតនោះទេ ។

- គ្រោងនឹងរៀបចំឱ្យមានការអនុវត្តដូចគ្នានេះដែរ ចំពោះការបង់ពន្ធលើអចលនទ្រព្យ។ អគ្គនាយកដ្ឋាន ពន្ធដារនឹងរៀបចំបញ្ចូលទិន្នន័យពាក់ព័ន្ធនឹងម្ចាស់អចលនទ្រព្យទៅក្នុងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីបង្កភាពងាយស្រួលដល់អ្នកជាប់ពន្ធ បើទោះបីជាអចលនទ្រព្យស្ថិតក្នុងតំបន់ណាក៏ដោយ ក៏ម្ចាស់អចលនទ្រព្យ អាចបង់ពន្ធលើអចលនទ្រព្យនៅតាមសាខាធនាគារ ឬនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ ដោយកាត់បន្ថយនូវពេលវេលា និងប្រាក់កាស ក្នុងការធ្វើដំណើរទៅបង់ពន្ធ គឺដោយគ្រាន់តែបង្ហាញប័ណ្ណសម្គាល់ ការបង់ពន្ធលើអចលនទ្រព្យនោះនៅតាមសាខាធនាគារ ឬនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ដែលនៅជិតខ្លួនបំផុតប៉ុណ្ណោះ។

- បន្តរៀបចំធ្វើបច្ចុប្បន្នភាពទិន្នន័យគ្រប់សហគ្រាសទាំងអស់ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងបណ្តាសហគ្រាសទាំងឡាយណា ដែលមានចេតនាគេចវេះ កេងបន្លំពន្ធ ឬប្រកាសបង់ពន្ធមិនត្រឹមត្រូវដើម្បីធានាបាននូវតម្លាភាពនិងសមភាពចំពោះអ្នកជាប់ពន្ធទាំងអស់។

- បន្តចាត់បញ្ជូនមន្ត្រីសវនករឱ្យចុះធ្វើសវនកម្ម លើសហគ្រាសក្នុងវិស័យដែលប្រាក់ពន្ធមានការថយចុះ ដើម្បីធានាបាននូវការប្រមូលចំណូលពន្ធប្រកបដោយតម្លាភាព និងប្រសិទ្ធភាពខ្ពស់។

- បន្តជំរុញអនុវត្តនូវគោលការណ៍ និងផែនការសកម្មភាពការងាររបស់អគ្គនាយកដ្ឋានពន្ធដារឱ្យបានដូចភ្លៀងរលឹមជាពិសេសយុទ្ធនាការនៃការចាត់បញ្ចូលទៅរបបស្វ័យប្រកាស នូវអាជីវកម្មបង់ពន្ធតាមរបបម៉ៅការដែលមានផលរបរខ្ពស់ ដោយដាក់ផែនការចាត់បញ្ចូលទៅក្នុងរបបស្វ័យប្រកាសឱ្យបាន ២០% នៃអាជីវកម្មដ្ឋានដែលស្ថិក្នុងរដ្ឋបាលដែនដីនៃខេត្ត-ខណ្ឌនីមួយៗ។

- បន្តអនុវត្តយ៉ាងម៉ឺងម៉ាត់ និងប្រកបដោយប្រសិទ្ធភាពខ្ពស់ នូវសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី០៣ ខែមករា ឆ្នាំ២០១៤ ស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

ជាកិច្ចបញ្ចប់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលមានការ

កើនឡើងគួរជាទីពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំបន្ថែមដល់អស់លោកជាប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់និងមន្ត្រីពន្ធដារទាំងអស់ឲ្យខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរ តាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសម្រេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៤។

**អគ្គនាយកដ្ឋានពន្ធដារ**